

## កម្មករការងារតាមផ្ទះមានសិទ្ធិទទួលបាន
## ប្រាក់ឈ្នួលដោយយុត្តិធម៌

# ការងារដូចគ្នានឹងការងារឯទៀតដែរ

ប្រសិនបើអ្នកធ្វើការជាកម្មករការងារតាមផ្ទះនៅប្រទេសថៃ អ្នកមានសិទ្ធិទទួលបានកិច្ចការពារនៅក្រោមច្បាប់ថៃ។ អ្នកត្រូវតែៈ

- ☐ ត្រូវមានអាយុច្រើនជាង 15 ឆ្នាំ ហើយអ្នកអាចទទួលបានកិច្ចគាំពារពិសេស ប្រសិនបើអ្នកមានអាយុតិចជាង 18 ឆ្នាំ។
- ☐ មានសិទ្ធិឈប់សំរាកយ៉ាងតិច 1 ថ្ងៃក្នុងមួយសប្តាហ៍ និងថ្ងៃឈប់សំរាកពេលមានបុណ្យជាតិ។
- ☐ ត្រូវទទួលបានប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងប្រសិនបើអ្នកធ្វើការនៅថ្ងៃបុណ្យជាតិ។
- ☐ មានសិទ្ធិបានឈប់សំរាកប្រចាំឆ្នាំដោយគ្មានការកាត់ប្រាក់ខែ។
- ☐ មានសិទ្ធិឈប់សំរាកពេលមានជម្ងឺដោយគ្មានការកាត់ប្រាក់ខែ។

បទបញ្ញាតិក្រសួងលេខ 14 (B.E.2555)

រាល់កម្មករការងារតាមផ្ទះទាំងអស់ដោយមិនគិតពីសញ្ជាតិមានសិទ្ធិទទួលបានការការពារដោយច្បាប់ការងារ។ អនុសញ្ញាស្តីពីការងារតាមផ្ទះ (C189) របស់អង្គការអន្តរជាតិខាងការងារផ្តល់ឲ្យកម្មករការងារតាមផ្ទះនូវសិទ្ធិៈ

- ☐ ទទួលបានប្រាក់ឈ្នួលដោយយុត្តិធម៌ និងម៉ោងការងារសមស្រប។
- ☐ យល់ដឹងអំពីអាណត្តិ និងល័ក្ខខ័ណ្ឌអំពីការងាររបស់ខ្លួន។
- ☐ ទទួលបានការការពារដោយរបបសន្តិសុខសង្គម។
- ☐ មានសេរីភាពរួចផុតពីការរំលោភបំពាន ការយាយី និងអំពើហឹង្សា។
- ☐ មានកន្លែងធ្វើការងារស្អាត និងមានសុវត្ថិភាព។
- ☐ មានបន្ទប់ដេកជាឯកជន មានសន្តិសុខ និងសុវត្ថិភាព។
- ☐ អាចចំណាយពេលទំនេររបស់ខ្លួន តាមចិត្តខ្លួនជ្រើសរើស។
- ☐ ទទួលបានប្រព័ន្ធការពារផ្នែកច្បាប់ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍។

ចូលរួមជាមួយយើងតាម online ដោយរកព័ត៌មានលំអិតនៅៈ

saphansiang.org/domesticworkers

facebook.com/convention189

International
Labour
Organization